ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ០២៣២ សអណ

**ជម្រាបមក**

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាព**
**រដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសវៀតណាម**

**កម្មវត្ថុ** ៖ ស្តីពីការពង្រឹងការគ្រប់គ្រងនិងការត្រួតពិនិត្យការចេញ-ចូលឆ្លងកាត់ព្រំដែន ដើម្បីបង្ការនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ប្រភេទថ្មីនៅកម្ពុជា។

**យោង** ៖ -លិខិតលេខ ១៨២ សជណ.មឃ ចុះថ្ងៃច័ន្ទ ៩កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-សេចក្តីណែនាំលេខ ០១៦ សណន ចុះថ្ងៃពុធ ២រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសវៀតណាម ជ្រាបថា កន្លងមកដើម្បីប្រយុទ្ធប្រឆាំងទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩នៅកម្ពុជា ក្រសួងមហាផ្ទៃបានដាក់ចេញសេចក្តីណែនាំលេខ០១៦ សណន ចុះថ្ងៃពុធ ២រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ស្តីពីការពង្រឹងផែនការបង្ការ ទប់ស្កាត់ និងបង្ក្រាបសកម្មភាពឆ្លងដែនដោយខុសច្បាប់ និងការលួចលាក់នាំជនបរទេសចេញពីភូមិសាស្ត្របិទខ្ទប់។ ដើម្បីរក្សាចំណងមិត្តភាព និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរខេត្តនៃព្រះរាជាណាចក្រកម្ពុជា និងអាជ្ញាធរខេត្តនៃសាធារណរដ្ឋសង្គមនិយមវៀតណាមដែលមានព្រំប្រទល់ជាប់គ្នានៅតំបន់ព្រំដែន និងដើម្បីបង្ការទប់ស្កាត់ការនាំជំងឺកូវីដ-១៩ ឆ្លងកាត់ព្រំដែនប្រទេសទាំងពីរ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដល់ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសវៀតណាម ត្រូវយកចិត្តទុកដាក់លើកិច្ចការដូចខាងក្រោម៖

- ត្រូវធ្វើការសម្របសម្រួលនិងទំនាក់ទំនងជាមួយអភិបាលខេត្តជាប់ព្រំដែននៃប្រទេសវៀតណាម ដើម្បីរៀបចំកិច្ចប្រជុំដោយផ្ទាល់ ដោយអនុវត្តតាមផែនការនានារបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ ឬកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពនៅតាមតំបន់ព្រំដែន ការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនាំមនុស្សឆ្លងដែនដោយខុសច្បាប់ ការរួមគ្នាក្នុងការបង្ការ ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅតាមតំបន់

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail : moi@interior.gov.kh web : www.interior.gov.kh

ព្រំដែននៃខេត្តនីមួយៗ ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការផ្លាស់ប្តូរទំនិញកសិផល គ្រឿងឧបភោគបរិភោគនៅតាមតំបន់ព្រំដែន សំដៅរួមគ្នាដោះស្រាយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតំបន់ព្រំដែនក្នុងកំឡុងពេលរីករាលដាលជំងឺកូវីដ-១៩។ បន្ទាប់ពីបញ្ចប់កិច្ចប្រជុំ រដ្ឋបាលខេត្តត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃកិច្ចប្រជុំជូនមកក្រសួងមហាផ្ទៃកុំបីខាន

– ត្រូវពង្រឹងអនុវត្តឱ្យបានតឹងរ៉ឹងនិងម៉ឺងម៉ាត់នូវវិធានការបង្ការ ទប់ស្កាត់ និងបង្រ្កាបសកម្មភាពឆ្លងដែនដោយខុសច្បាប់ឱ្យមានប្រសិទ្ធភាព តាមស្មារតីនៃសេចក្តីណែនាំលេខ ០១៦ សណន ចុះថ្ងៃពុធ ២រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ

– បន្តជំរុញអប់រំ ណែនាំ និងផ្សព្វផ្សាយដល់សាធារណជននិងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន ជាពិសេសប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ព្រំដែនឱ្យបង្កើនការប្រុងប្រយ័ត្នការពារខ្លួនស្របតាមវិធានការរបស់ក្រសួងសុខាភិបាល និងវិធានការពារ ៣កុំ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីកុំឱ្យមានមេរោគកូវីដ-១៩ ឆ្លងមកលើបុគ្គលនិងសហគមន៍មូលដ្ឋាន។

អាស្រ័យហេតុនេះ សូម ឯកឧត្តម ជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម ឯកឧត្តម ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ថ្ងៃ ព្រហ.០៤រោច ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០២១

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការពារជាតិ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ